# មហារីកប្រូ៉ស្តេត(Prostate)



ប្រូ៉ស្តេតគឺជាក្រពេញនៅក្រោមប្លោកនោមបុរស ដែលផលិតជាតិទឹកសំរាប់ទឹកកាម។

មហារីកប្រូ៉ស្តេតគឺជាផ្នែកចំបងនៃការមរណៈពី មហារីកធំទីបីក្នុងចំណោមបុរសគ្រប់អាយុទាំងអស់។

វាកម្រឃើញមានក្នុងចំណោមបុរសអាយុតិចជាង40ឆ្នាំ។

កំរិតនៃសារធាតុដែលរកឃើញនៅក្នុងឈាមហៅថាអតិសុខុមប្រាណជាក់លាក់នៃប្រូ៉ស្តេត(prostate specific antigen)PSA ដែលធម្មតាមានកំរិតខ្ពស់ ចំពោះបុរសដែលមានមហារីកប្រូ៉ស្តេត។ តែទោះជាយ៉ាងណាការធ្វើតេស្តឈាម PSA អាចមានកំរិតខ្ពស់ ក្នុងលក្ខណជំងឺ ប្រូ៉ស្តេតដ៏ទៃៗទៀតផងដែរ ដូចជាដំបៅឬក្រពេញរីកធំ។



អ្នកវិទ្យាសាស្រ្តកំពុងតែរៀនសូត្រថែមទៀតអំពីជំរើសពិនិត្យជំងឺមហារីកប្រូ៉ស្តេតរៀងរាល់ពេលទាំងអស់។ ពិភាក្សាជាមួយវេជ្ជបណ្ឌិតរបស់អ្នក អំពី ពេលណានិងអ្វីដែលការធ្វើតេស្តមហារីក រួមទាំងតេស្តប្រូ៉ស្តេតPSA ដែលប្រសើរបំផុតសំរាប់អ្នក។

ដោយតេស្ត PSA ក្លាយជាធម្មតាស្ទើរតែគ្រប់មហារីកប្រូ៉ស្តេតត្រូវបានរកឃើញនៅមុនពេលនឹងមានរោគសញ្ញាកើតឡើង។

មានរោគសញ្ញាជាច្រើនយ៉ាងនៃជំងឺ មហារីកប្រូ៉ស្តេតបើអ្នកមានរោគសញ្ញាដូចតទៅនេះ សូមជួបគ្រូពេទ្យអ្នក។



- បញ្ហាពិបាកបត់ជើងតូចដូចជា ឈឺមានការពិបាកពេលចាប់ផ្តើមនោម ឬ នោម មិនចេញ ឬ ស្រក់តក់ៗ

- ឈឺចង្កេះ

- ឈឺពេលបញ្ចេញទឹកកាម

ការព្យាបាលជំងឺមហារីកប្រូ៉ស្តេតជាញឹកញយគឺអាស្រ័យលើដំណាក់កាលនៃជំងឺមហារីក។ តើមហារីកនោះរីកដុះដាលរហ័សប៉ុណ្ណាហើយភាពខុសគ្នានៃជាលិកានៅជុំវិញវាអាចជួយឲ្យគេកំណត់ពីដំណាក់កាលវាបាន។

- ការព្យាបាលអាចមានរួមនូវការវះកាត់, វិធីព្យាបាលដោយប្រើចំហាយជាតិវិទ្យុសកម្ម, ការព្យាបាលមហារីកដោយថ្នាំឬការត្រួតត្រាជាតិអ័រម៉ូនដែលប៉ះពាល់ដល់មហារីក។





**A project by Health Roads Media and EthnoMed**
This project has been funded in whole or in part with Federal funds from the Department of Health and Human Services, National Institutes of Health, National Library of Medicine, under Contract No. HHS-N-276-2011-0008-C with the University of Washington. Thank you to Safeway Foundation for its support to Harborview Medical Center's EthnoMed for the development of cancer-related content.

www.healthyroadsmedia.org and http://ethnomed.org
Prostate Cancer – Khmer (last reviewed June 2013